**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

## ស្តីពីការព្យួរការងារ ក្នុងក្រុមហ៊ុន ខេមកាស៊ីន(ខេមបូឌា) ហ្គាមិន ឯ.ក

ឆ្នាំពីរពាន់ម្ភៃបួន ខែមីនា ថ្ងៃទីដប់ប្រាំបី វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក នៅក្នុង ក្រុមហ៊ុន ខេមកាស៊ីន (ខេមបូឌា) ហ្គាមិន ឯ.ក បានបើកកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន ខេមកាស៊ីន (ខេមបូឌា) ហ្គាមិន ឯ.ក និងសហជីពកម្ពុជាដើម្បីសិទ្ធិកម្មករ ប្រចាំក្រុមហ៊ុន,តំណាងកម្មករនិយោជិត(ប្រតិភូបុគ្គលិក),ប្រធានក្រុម,ប្រធានផ្នែក ទាំងអស់ក្នុងក្រុមហ៊ុន ដែលមានទីតាំងស្ថិតនៅភូមិព្រៃព្រីងខាងជើង២ សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ក្រោយពីបានពិភាក្សាឆ្លងរួចរាល់ ភាគីទាំងសងខាង បានឯកភាព និងព្រមព្រៀង ដូចខាងក្រោម៖

ប្រការ១៖ ភាគីទាំងពីរបានព្រមព្រៀង និងឯកភាពគ្នា ឲ្យក្រុមហ៊ុនព្យួរការងារកម្មករចំនួន៦៣២នាក់ (ស្រី ៥៧២នាក់) ក្នុងចំនោមកម្មករសរុប ៧៦០នាក់ (ស្រី ៦៥២នាក់) ចំនួន១២ថ្ងៃ ដោយមូលហេតុខ្វះវត្ថុធាតុដើម និងការបញ្ជាទិញ ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៤ ដោយ ក្រុមហ៊ុនផ្តល់ជូនប្រាក់ឧបត្ថម្ភនិងអត្ថប្រយោជន៍ ជូនកម្មករនិយោជិត ដូចខាងក្រោម៖

- ថ្ងៃទី០១ រហូតដល់ថ្ងៃទី១២ ខែមេសា ឆ្នាំ ២០២៤ មានរយៈពេល ១២ថ្ងៃ ក្រុមហ៊ុនផ្តល់ជូនប្រាក់ឧបត្ថម្ភ ជូនកម្មករនិយោជិត ៥០% (ហាសិបភាគរយ)នៃប្រាក់ឈ្នួលគោល រយៈពេល១១ថ្ងៃ
- ក្រុមហ៊ុនផ្តល់ជូនប្រាក់ស្នាក់នៅ និងធ្វើដំណើរចំនួន១០ដុល្លារ/ម្នាក់ជូនកម្មករនិយោជិតដដែល។
- ក្រុមហ៊ុនសូមមិនផ្តល់ជូន ប្រាក់លើកទឹកចិត្ត (ប្រាក់សហការចំនួន១០ដុល្លារ) ជូនកម្មករនិយោជិតនោះទេ
- ក្រុមហ៊ុន ផ្តល់ជូន ប្រាក់ការងារទៀងទាត់ (លុយព្រីម) ចំនួន៥ដុល្លារ ជូនកម្មករនិយោជិត នៅពេលកម្មករនិយោជិតចូលធ្វើការវិញចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤។
- ចំពោះការបើកប្រាក់ឈ្នួលប្រចាំខែមិនា ឆ្នាំ២០២៤ ត្រូវបើកនៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០២៤
- ចំពោះការបើកប្រាក់ឧបត្ថម្ភកំឡុងពេលព្យួរការងារ ត្រូវបើកនៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០២៤

ប្រការ៣៖ កម្មករនិយោជិតទាំងអស់ត្រូវបានឈប់សម្រាកចំនួន១២ថ្ងៃ នឹងត្រូវចូលបំពេញការងារវិញនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៤។

ប្រការ៤៖ ក្នុងករណីភាគីណាមួយមិនគោរពតាមកិច្ចព្រមព្រៀងនេះ នឹងទទួលខុសត្រូវចំពោះមុខច្បាប់ជា ធរមាន កិច្ចព្រមព្រៀងនេះភាគីទាំងពីរត្រូវគោរព និងអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខា និងផ្តិតមេដៃនេះតទៅ។

ភ្នំពេញ,ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤

**ហត្ថលេខា និងត្រា ភាគីក្រុមហ៊ុន**

**នាយក**

ព្រះរាជាណាចក្រកម្ពុជា
CAMKAXIN (CAMBODIA) GARMENT CO.,LTD.
KINGDOM OF CAMBODIA

wang shujun

## ដភាគី តំណាងឱ្យកម្មករនិយោជិត និងតំណាងសហជីព

| | | |
|---|---|---|
| ១-លោក សំ ផានិត ប្រធានសហជីព | | ........................ |
| ២-លោកស្រី ស៊ឹម សុខណាត្រី | តំណាងកម្មករ | ........................ |
| ៣-លោក ឃិន ដារ៉ូ | តំណាងកម្មករ | ........................ |
| ៤-លោកស្រី សាក់ ដួងច័ន្ទ | តំណាងកម្មករ | ........................ |
| ៥-លោក ចយ សារ៉ាយ | តំណាងកម្មករ | ........................ |
| ៦-អ្នកនាង នាក់ លក្ខិណា | តំណាងកម្មករ | ........................ |
| ៧-លោកស្រី សឿន សុគន្ធារី | តំណាងកម្មករ | ........................ |
| ៨-លោកស្រី ហង់ ស្រីពៅ | តំណាងកម្មករ | ........................ |
| ៩-លោកស្រី សាក់ ដួងច័ន្ទ | តំណាងកម្មករ | ........................ |
| ១០-លោកស្រី ជិន សារី | ប្រធានជំក្រុមដេរ១-៣ | ........................ |
| ១១-លោកស្រី គីម សំណាង | ប្រធានជំក្រុមដេរ៤-៥ | ........................ |
| ១២-លោកស្រី សុខ ខេម | ប្រធានជំក្រុមដេរ៦ | ........................ |
| ១៣-លោកស្រី យ៉ាំ ហន | ប្រធានជំក្រុមដេរ១០-១១ | ........................ |
| ១៤-លោកស្រី សុខ សាវ៉ាន | ប្រធានជំក្រុមដេរ១២-១៤ | ........................ |
| ១៥-លោកស្រី នឹម ស្រីឡា | ប្រធានក្រុមដេរទី១ | ........................ |
| ១៦-លោកស្រី ស៊ាង គន្ធី | ប្រធានក្រុមដេរទី៤ | ........................ |
| ១៧-លោកស្រី ជា លក្ខណា | ប្រធានក្រុមដេរទី៥ | ........................ |
| ១៨-លោកស្រី ស៊ន ស្រីរត្ន័ | ប្រធានក្រុមដេរទី៧ | ........................ |
| ១៩-លោកស្រី សួន វ៉ាន់ណេន | ប្រធានក្រុមដេរទី៨ | ........................ |

CAMKAXIN (CAMBODIA) GARMENT CO., LTD.
KINGDOM OF CAMBODIA

Scanned with CamScanner